ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ១១ កើត ខែកត្តិក ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន

ស្តីពីជំនួបពិភាក្សាការងាររវាង
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ជាមួយ ឯកឧត្តម SUZUKI Hideo, ឧបការីរដ្ឋមន្ត្រី និងជាអគ្គនាយក នៃអគ្គនាយកដ្ឋាន
សហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេសជប៉ុន

នាព្រឹកថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម SUZUKI Hideo ឧបការីរដ្ឋមន្ត្រី និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការបរទេសជប៉ុន ក្នុងខណៈដែលឯកឧត្តមមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ។ ក្នុងឱកាសនៃជំនួបពិភាក្សានេះ ឯកឧត្តម Masahiro MIKAMI ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ក៏បានអញ្ជើញចូលរួមផងដែរ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវក្តីសោមនស្ស និងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានឯកឧត្តម SUZUKI Hideo ដែលបានអញ្ជើញមកបំពេញភារកិច្ចនៅកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអរគុណចំពោះប្រទេសជប៉ុន និងប្រជាជនជប៉ុន ដោយបានគូសបញ្ជាក់ថា ប្រទេសជប៉ុន និងប្រជាជនជប៉ុន បានរួមចំណែកយ៉ាងសកម្មក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសកម្ពុជា ចាប់តាំងពីដំណើរការស្វែងរកសន្តិភាពរហូតមកដល់បច្ចុប្បន្ននេះ ។ ជាក់ស្តែង សមិទ្ធផលផ្លែផ្កាជាច្រើនដែលកម្ពុជាសម្រេចបាន មានការចូលរួមចំណែក និងគាំទ្រយ៉ាងសកម្ម ទាំងធនធានហិរញ្ញប្បទាន និងជំនួយបច្ចេកទេសពីប្រទេសជប៉ុន និងប្រជាជនជប៉ុន ។

ឯកឧត្តម SUZUKI Hideo បានសម្តែងនូវសេចក្តីសប្បាយរីករាយ ដែលបានមកបំពេញកិច្ចការនៅព្រះរាជាណាចក្រកម្ពុជា និងបានសម្តែងនូវការកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបាននាំមកនូវការអភិវឌ្ឍជាច្រើនឥតគណនាក្នុងផ្នែកសង្គម-សេដ្ឋកិច្ច និងការរីកចម្រើនលើគ្រប់វិស័យពិសេស កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យម ៧% ក្នុងមួយឆ្នាំ ដែលបានធ្វើឲ្យប្រទេសកម្ពុជាប្រែក្លាយពីប្រទេសដែលធ្លាប់មានចំណូលទាប (Low-Income Country) ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (Lower Middle-Income Country) ។

ឯកឧត្តម SUZUKI Hideo ក៏បានគូសបញ្ជាក់ផងដែរថា ប្រទេសជប៉ុន និងរដ្ឋាភិបាលជប៉ុន នឹងបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធគ្រប់វិស័យជាមួយប្រទេសកម្ពុជា និងបន្តពង្រីក និងពង្រឹងទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំថែមទៀត តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការ និងការគាំទ្រក្នុងវិស័យនានារួមទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ក៏ដូចជាការជំរុញដល់ការអភិវឌ្ឍវិស័យឯកជននានា ឲ្យកាន់តែរីកចម្រើនបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងវិស័យអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាមួយគ្នានេះដែរ ប្រទេសជប៉ុនក៏នឹងបន្តផ្តល់ការគាំទ្រ និងជំរុញរាល់គ្រប់សកម្មភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ដូចជា កិច្ចសហប្រតិបត្តិការ មេគង្គ-ជប៉ុន និង អាស៊ាន-ជប៉ុន ជាដើម ។

ជារួម ប្រទេសជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានសន្យាផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (Japanese ODA) ដល់ព្រះរាជាណាចក្រកម្ពុជាសរុបចំនួនប្រមាណជាង ៥ ០០០ លានដុល្លារអាមេរិក ក្នុងនោះមានហិរញ្ញប្បទានឥតសំណងប្រមាណជាង ៣ ៥០០ លានដុល្លារអាមេរិក ។ តួលេខនេះ មិនរាប់បញ្ចូលកិច្ចសហប្រតិបត្តិការបច្ចេកទេស និងគម្រោងនានាដែលត្រូវបានផ្តល់ដោយប្រជាជន និងសប្បុរសជនជប៉ុន ជូនដល់ប្រជាជនកម្ពុជាដោយផ្ទាល់ឡើយ ។

***************